# សេចក្តីថ្លែងការណ៍

# អង្គការតម្លាភាពកម្ពុជាបញ្ជាក់ពីការមិនចូលរួមសង្កេតការណ៍ក្នុងការប្រឡងបាក់ឌុបថ្នាក់ជាតិប្រចាំឆ្នាំ ២០១៤

**រាជធានីភ្នំពេញ,** ថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៤ – អង្គការតម្លាភាពកម្ពុជា (TI Cambodia) បញ្ជាក់ពីការមិនចូលរួមរបស់ខ្លួនក្នុងការក្នុងការត្រួតពិនិត្យដំណើរការប្រឡងបាក់ឌុបថ្នាក់ជាតិនាខែសីហា ឆ្នាំ២០១៤ នេះ ដោយសារតែលក្ខខណ្ឌដែលបានទាមទារមិនអនុញ្ញាតឱ្យអង្គការតម្លាភាពកម្ពុជាប្រើវិធីសាស្ត្រដែលមានលក្ខណៈជាប្រព័ន្ធ និងតាមបែបវិទ្យាសាស្ត្រដែលហៅថា ការសង្កេតការណ៍តាមសំណាកគំរូ (Sample Base Observation or SBO)។ SBO គឺជាវិធីសាស្ត្រសង្កេតការណ៍ការប្រឡងមួយដែលប្រើប្រាស់ស្ថិតិជាតំណាងនៃសំណាកគំរូដើម្បីវាយតម្លៃប្រកបដោយភាពជាក់លាស់នៃគុណភាពនៃដំណើរការប្រឡងនៅក្នុងថ្ងៃប្រឡង។

យោងតាមសេចក្តីថ្លែងការណ៍របស់អង្គភាពប្រឆាំងអំពើពុករលួយ (ACU) ដែលបានចេញសេចក្តីប្រកាសអញ្ជើញភាគីពាក់ព័ន្ធទាំងអស់ក្នុងនោះរួមមាន អង្គការមិនមែនរដ្ឋាភិបាល អង្គការសង្គមស៊ីវិល ក្រុមហ៊ុនឯកជន និងបុគ្គលឯកជននានា ដើម្បីចូលរួមសង្កេតការប្រឡងថ្នាក់ជាតិ នាខែសីហា ឆ្នាំ២០១៤ ខាងមុខនេះ។ អង្គការតម្លាភាពកម្ពុជាក៏បានផ្សព្វផ្សាយដំណឹងជ្រើសរើសអ្នកស្ម័គ្រចិត្តដើម្បីធ្វើការសង្កេតការប្រឡងថ្នាក់ជាតិនេះដែរ។ អ្នកសង្កេតការណ៍អង្គការតម្លាភាពកម្ពុជានឹងត្រូវបានដាក់ពង្រាយនៅទូទាំងប្រទេសនៅតាមមណ្ឌលប្រឡងដែលត្រូវបានជ្រើសរើស ដើម្បីប្រមូលព័ត៌មានទាក់ទងនៅនឹងបរិយាកាស និងដំណើរការប្រឡង។ ដោយសារតែមណ្ឌលប្រឡងសំណាកគំរូគឺជាស្ថិតិតំណាងអោយមណ្ឌលប្រឡងទាំងអស់នោះ របាយការណ៍របស់អ្នកសង្កេតការណ៍នេះ ក៏តំណាងអោយដំណើរការប្រឡងនៅទូទាំងប្រទេសផងដែរ។ ការអវត្តមានរបស់អ្នកសង្កេតការណ៍ណាមួយនឹងជះនូវឥទ្ធិពលយ៉ាងខ្លាំងដល់លទ្ធផលនៃរបាយការណ៍នេះដែលអាចធ្វើឱ្យរបាយការណ៍នេះក្លាយជាមោឃៈ ដូច្នេះហើយអង្គការតម្លាភាពកម្ពុជាតម្រូវ ឱ្យមានអ្នកសង្កេតការណ៍បម្រុងជាចាំបាច់។ ក៏ប៉ុន្តែអង្គការតម្លាភាពកម្ពុជាមិនត្រូវបានអនុញ្ញាតឱ្យមានអ្នកសង្កេតការណ៍បម្រុងនោះទេ។

**Contact:**
Transparency International Cambodia, Mr. Pech Pisey, Email: piseypech@ticambodia.org - Phone +855 89 972 620